


# មាតិកា

ទំព័រ


២ តើទំនាក់ទំនងជាអ្វី ?

៤ ការបង្កើតសារតស៊ូមតិ

៦ ការបញ្ជូនសារតស៊ូមតិ

៨ ការយល់ដឹងអំពីអំណាចនៅក្នុងសង្គម

១០ អំណាចរដ្ឋាភិបាល

១២ ដំណើរការធ្វើច្បាប់

១៤ ការព្រាងច្បាប់

១៥ ការបញ្ចុះបញ្ចូល

១៨ ផែនការទំនាក់ទំនងជាយុទ្ធសាស្ត្រជាមួយរដ្ឋាភិបាល

១៩ ការជួបជាមួយសមាជិករដ្ឋាភិបាល

២១ សន្ទានុក្រម និង ឯកសារយោង



**អ្នកនិពន្ធ**

លោក ស៊ីន ហ្គ្រាលតុន, លោក ខូលីន ប៊ុន និង កញ្ញា វីកធ័រវៀ អេយើ

Sean Gralton, Colin Bunn, Victoria Ayer

**អ្នកកែសម្រួល**

លោក ឃឹត ម៉ាកឡៅដ៏, លោក នី កែវប៉ុញ្ញា, អ្នកស្រី ជា ចាន់ឌី, លោក រស់ សុដ្ឋា, លោក ប៉ុល ហំម, កញ្ញា ជេស៊ី ហ្វ្រីម៉ែន, លោក យ៉ាប់ មេត្តា, ផេក កម្ពុជា

លោក ម៉ៃក បឺដ, អុកស្វាម អង់គ្លេស

លោក ឈិត សំអាត, ស៊ីដសេ

លោកជំទាវ មូ សុខហួរ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និង អតីតយុទ្ធជន

Kurt MacLeod, Ny KeoPonha, Chea Chandy, Ros Sotha, Pol Ham, Jessie Freeman, Yoib Meta, **Pact Cambodia**

Mike Bird, **OXFAM GB**

Chhith Sam Ath, CIDSE

Mu Sochua, **Cambodian Minister of Women's & Veteran's Affairs**

**អ្នកតាក់តែងរូបភាព**

លោក ខូលីន ប៊ុន

Colin Bunn

# សេចក្តីផ្តើម

មន្ត្រីរដ្ឋាភិបាល អ្នកបញ្ញត្តិច្បាប់ និង បុគ្គលិករបស់គាត់ មានអំណាចយ៉ាងធំធេងទៅលើជោគជ័យនៃយុទ្ធនាការតស៊ូមតិ។ ការគាំទ្រ ឬ ការប្រឆាំងរបស់គាត់អាចជះឥទ្ធិពលបានយ៉ាងខ្លាំងក្លាលើទិសដៅនៃយុទ្ធនាការតស៊ូមតិ។ គោលបំណងនៃសៀវភៅទី ២ នៃ កម្រងអត្ថបទសម្រាប់អ្នកជំនាញតស៊ូមតិនេះ គឺដើម្បីពិនិត្យមើលថា តើអង្គការមិនមែនរដ្ឋាភិបាលអាចបង្កើតទំនាក់ទំនងរឹងមាំជាមួយសមាជិករដ្ឋាភិបាល និង បញ្ចុះបញ្ចូលគាត់បានយ៉ាងណាឱ្យបំពេញគោលបំណងតស៊ូមតិរបស់យើង។

## ទំនាក់ទំនងភ្ជាប់យុទ្ធនាការតស៊ូមតិរបស់យើងជាមួយរដ្ឋាភិបាល

ជោគជ័យនៃយុទ្ធនាការតស៊ូមតិរបស់យើង គឺអាស្រ័យលើការប៉ិនប្រសប់របស់យើងក្នុងការបញ្ចុះបញ្ចូលអ្នកមានអំណាចឱ្យបំពេញគោលបំណងតស៊ូមតិរបស់យើង។ ដើម្បីបញ្ចុះបញ្ចូលគាត់បាន ជាដំបូងយើងត្រូវតែយល់ដឹងអំពីរបៀបទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និង ដឹងថាតើអំណាចអាចដំណើរការបានយ៉ាងដូចម្តេច។

**ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព** + **ការយល់ដឹងអំពីអំណាច** = **ការប៉ិនប្រសប់ក្នុងការបញ្ចុះបញ្ចូល**

# តើទំនាក់ទំនងជាអ្វី ?

ទំនាក់ទំនង គឺជាវិធីមួយក្នុងការផ្ទេរគំនិតនានាទៅឱ្យមនុស្សដទៃ។ គំនិតទាំងនេះអាចមានលក្ខណៈសាមញ្ញ ដូចជា "យើងក្រីក្រ" ឬក៏ "យើងឃ្លាន"។ គំនិតនៃយុទ្ធនាការតស៊ូមតិ ទាមទារនូវសកម្មភាព ឧទាហរណ៍ "បន្ថែមចំនួនគ្រូបង្រៀន" ឬ "អភិរក្សព្រៃឈើរបស់យើង ដោយការពង្រឹងច្បាប់សហគមន៍ព្រៃឈើ "។

ទំនាក់ទំនងដ៏ស័ក្តិសិទ្ធិ គឺជាមូលដ្ឋានគ្រឹះនៃយុទ្ធនាការតស៊ូមតិរបស់យើង។ តាមរយៈទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពនេះ យើងអាច កៀរគរអ្នកគាំទ្ររបស់យើង ហើយក៏អាចបញ្ចុះបញ្ចូលអ្នកមានអំណាចឱ្យផ្លាស់ប្តូរ ឬ អនុវត្តគោលនយោបាយបានដែរ។

## តើយើងអាចប្រាស្រ័យទាក់ទងយ៉ាងស័ក្តិសិទ្ធិបានដោយរបៀបណា ?

ជារឿយៗ យើងប្រាស្រ័យទាក់ទងតាមរយៈការនិយាយ ឬ សរសេរ។ ទោះបីជាវិធីទាំងពីរនេះជាវិធីធ្វើទំនាក់ទំនងដ៏ប្រសើរយ៉ាងណាក៏ដោយ ក៏មិនមែនសុទ្ធតែមានប្រសិទ្ធភាពបំផុតនោះឡើយ។ ជួនកាលរូបភាពតែមួយប៉ុណ្ណោះអាចបញ្ជូនសារមួយដែលមានឥទ្ធិពលស្មើនឹងពាក្យពេចន៍ចំនួនមួយពាន់ម៉ាត់។ បើទាក់ទងថែមទៀតទៅនឹងយុទ្ធនាការតស៊ូមតិរបស់យើង យើងអាចមើលឃើញថាការប្រមូលផ្តុំមនុស្សមួយពាន់នាក់ អាចមានភាពស័ក្តិសិទ្ធិជាងពាក្យពេចន៍ចំនួនមួយពាន់ម៉ាត់ទៅទៀត។



ការតវ៉ាធ្វើទំនាក់ទំនងតាមរយៈ**សកម្មភាព**



**គាំទ្រការដំឡើងប្រាក់ខែគ្រូបង្រៀន**

១. គ្រូបង្រៀនត្រូវការប្រាក់បៀវត្សន៍ដែលអាចរស់បាន សមស្របទៅនិងចំនួនម៉ោងសម្រាប់រៀបចំមេរៀន។

២. គ្រូបង្រៀន ត្រូវការរកប្រាក់គ្រប់គ្រាន់ដើម្បីទ្រទ្រង់ខ្លួនឯង។

៣. គ្រូបង្រៀន ត្រូវមានផែនការប្រាក់សោធន-និវត្តន៍ និង ប្រាក់បំណាច់ដើម្បីទ្រទ្រង់ខ្លួនឯងពេលចូលនិវត្តន៍។

ខិត្តប័ណ្ណធ្វើទំនាក់ទំនងតាមរយៈ**ការសរសេរ**

**ដើម្បីក្លាយទៅជាអ្នកប្រាស្រ័យទាក់ទងដ៏ល្អ យើងត្រូវធ្វើជាអ្នកស្តាប់ដ៏ល្អជាមុនសិន ។**

# អ្វីទៅជាការស្តាប់យ៉ាងសកម្ម ?

រាល់យុទ្ធនាការតស៊ូមតិប្រកបដោយជោគជ័យទាំងអស់ ចាប់ផ្តើមឡើងដោយការស្តាប់យ៉ាងសកម្ម ពោលគឺការស្តាប់យ៉ាងប្រុងប្រយ័ត្ន និង មានចម្លើយតបចំពោះមនុស្សនៅក្នុងបណ្តាសហគមន៍ដែលទទួលរងនូវការប៉ះពាល់ ដើម្បីស្វែងយល់ពីបញ្ហារបស់គាត់។ ការស្តាប់យ៉ាងសកម្ម គឺជាដំណើរការស្តាប់គំនិត ឬ មតិរបស់នរណាម្នាក់។ ការស្តាប់យ៉ាងសកម្ម ផ្តល់នូវការគោរពដល់មនុស្សដែលយើងកំពុងប្រាស្រ័យទាក់ទងជាមួយ ដោយបង្ហាញថាយើងកំពុងតែខិតខំស្វែងយល់នូវគំនិត និង មតិយោបល់របស់គាត់យ៉ាងពិតប្រាកដ។ នៅពេលដែលយើងគោរពនូវគំនិត និង មតិយោបល់របស់អ្នកដទៃ យើងអាចរំពឹងថាគេនឹងស្តាប់យើងយ៉ាងសកម្មវិញដែរ។ ការស្តាប់យ៉ាងសកម្មក៏ :

- បញ្ជាក់ផងដែរនូវការយល់ដឹងរបស់យើងចំពោះអ្វីដែលគេបាននិយាយមកកាន់យើង។
- បង្ហាញយើងផងដែរនូវផ្នែកណាមួយនៃសាររបស់យើង ដែលនៅមិនទាន់ច្បាស់លាស់ ឬ មិនអាចយល់បាន។
- ជួយផងដែរក្នុងការបង្កើតនូវទំនាក់ទំនងការងារល្អ។ មនុស្សគ្រប់គ្នាតែងតែចង់ដឹងថា តើគេកំពុងស្តាប់ និង គោរពនូវគំនិត និង មតិយោបល់របស់ខ្លួនដែរឬទេ។

## តើយើងអាចស្តាប់យ៉ាងសកម្មបានដោយរបៀបណា ?

ដើម្បីស្តាប់យ៉ាងសកម្ម យើងត្រូវ :

- សួរសំណួរ ប្រសិនបើយើងមិនយល់។
- ថ្លែងឡើងវិញនូវអ្វីដែលអ្នកនិយាយម្ខាងទៀតបាននិយាយហើយ បន្ទាប់មកសួរគាត់ថា តើអ្វីដែលខ្ញុំថ្លែងឡើងវិញត្រឹមត្រូវដែរឬទេ?
- ប្រើក្រសែភ្នែក និង ភាសាកាយវិការ ដូចជា ងក់ក្បាល ដើម្បីបង្ហាញថាយើងកំពុងស្តាប់ដោយយកចិត្តទុកដាក់។
- អត់ធ្មត់ ដើម្បីអោយអ្នកនិយាយនោះមានឱកាសបញ្ចេញគំនិតរបស់គេផ្ទាល់។

ក្នុងអំឡុងពេលនៃយុទ្ធនាការរបស់យើង យើងត្រូវស្តាប់យ៉ាងសកម្មចំពោះនរណាម្នាក់ដែលទទួលសារតស៊ូមតិរបស់យើង។

**ខ្សែរង្វង់នៃការស្តាប់យ៉ាងសកម្ម**




**ការផ្តល់ និង ការទទួលយោបល់ត្រឡប់ គឺជាគន្លឹះនៃការស្តាប់យ៉ាងសកម្ម ។**

# ការបង្កើតសារតស៊ូមតិ

ជារៀងរាល់ថ្ងៃ យើងទទួលបានសារជាច្រើនពីប្រភពជាច្រើន ដូចជា វិទ្យុ ទូរទស្សន៍ សារព័ត៌មាន ការផ្សាយពាណិជ្ជកម្ម សាលារៀន សិក្ខាសាលា កិច្ចប្រជុំ ព្រមទាំងពីមិត្តភក្តិ និង គ្រួសារផង។ ប៉ុន្តែយើងមិនអាចមានលទ្ធភាពដើម្បីប្រើប្រាស់គ្រប់ព័ត៌មានទាំងនោះនៅក្នុងពេលតែមួយបានទេ។ អង្គគោលដៅនៃយុទ្ធនាការតស៊ូមតិរបស់យើង ("អ្នកពាក់ពន្ធ័" ដែលមានឥទ្ធិពលខ្ពស់ទៅលើគោលបំណងរួមនៃយុទ្ធនាការតស៊ូមតិរបស់យើង) ក៏មានលក្ខណៈមិនខុសប្លែកគ្នាដែរ។

ដើម្បីផ្សព្វផ្សាយឱ្យដឹងពីសារតស៊ូមតិរបស់យើងប្រកបដោយប្រសិទ្ធភាពនោះ យើងចាំបាច់ត្រូវជ្រើសរើសដោយយកចិត្តទុកដាក់នូវខ្លឹមសារ ភាសា និង ប្រភេទផ្លាកសញ្ញានៃសាររបស់យើង។

**ខ្លឹមសារ** តើយុទ្ធនាការរបស់យើងស្តីអំពីអ្វី ? តើយើងនឹងប្រើប្រាស់នូវទឡ្ហីករណ៍អ្វីខ្លះ ដើម្បីឱ្យអង្គគោលដៅជឿ ?

**សាមញ្ញ**

យុទ្ធនាការតស៊ូមតិរបស់យើងគួរតែមានសារចំបងមួយ និង មានសារគាំទ្រមិនលើសពីបី។ ប្រសិនបើយើងមានច្រើនថែមទៀត យើងនឹងបាត់បង់នូវការយកចិត្តទុកដាក់ពីអង្គគោលដៅរបស់យើង។

**ខ្លី**

សារ គឺជាគំនិតដែលអាចពន្យល់បានត្រឹមមួយ ឬ ពីរប្រយោគ។ ប្រសិនបើយើងចាំបាច់ប្រើប្រាស់កថាខណ្ឌមួយ ឬ ច្រើនជាងនេះ យើងគួរតែបំប្រួញសាររបស់យើង។

**មានការទាក់ទង**

សាររបស់យើងជានិច្ចកាលត្រូវតែគាំទ្រដល់គោលបំណងរួមសំខាន់នៃការតស៊ូមតិរបស់អង្គការយើង។

**ច្បាស់លាស់**

វិធីដ៏ស័ក្តិសិទ្ធិបំផុតនៃទំនាក់ទំនង គឺជាអ្វីទាំងឡាយណាដែលគេមិនអាចបកស្រាយខុសបាន។ ឧទាហរណ៍ :



ទារកម្នាក់អាចយំ ពីព្រោះទារកនោះ អស់កម្លាំង ឬ ឃ្លាន...



ម៉ូតូមួយគ្រឿងអាចមិនឆេះ ពីព្រោះវាអស់សាំង ឬ អស់ភ្លើងអាគុយ...



ភ្លើងចរាចរពណ៌ក្រហម មានន័យថាឈប់ គេមិនអាចបកប្រែផ្សេងពីនេះឡើយ។ យើងគួរតែមានលក្ខណៈច្បាស់លាស់ដូចភ្លើងចរាចរអីចឹង។

## ភាសា តើយើងនឹងប្រើប្រាស់ពាក្យគន្លឹះអ្វីខ្លះដើម្បីផ្តល់ទៅឱ្យអង្គគោលដៅរបស់យើង ? ហើយតើយើងត្រូវជៀសវាងពាក្យអ្វីខ្លះ ?

ភាសាដែលយើងប្រើប្រាស់នៅក្នុងសារតស៊ូមតិរបស់យើងត្រូវតែជា ៖

**ការថ្លែងពីគំនិត**

សារគួរតែជាគំនិតដ៏ពេញលេញមួយ ដែលអាចធ្វើឱ្យគេយល់បានយ៉ាងរហ័ស និង ដោយងាយស្រួល។ យើងអាចប្រើប្រាស់បានផងដែរនូវការប្រៀបធៀបយ៉ាងប៉ិនប្រសប់ ភាសាដ៏រស់រវើក និង ព័ត៌មានដ៏ពិស្តារ ដើម្បីបង្កើននូវឥទ្ធិពលនៃសាររបស់យើង។

**មិនផ្លាស់ប្តូរ**

សារនានានឹងចាំបាច់ត្រូវធ្វើម្តងហើយម្តងទៀត ដើម្បីឱ្យគេបានឮ និង បានយល់។ យើងគួរតែប្រើប្រាស់ភាសាស្រដៀងគ្នានៅក្នុងសារទាំងអស់របស់យើង ប្រសិនបើយើងចង់ឱ្យអង្គគោលដៅយើងភ្ជាប់សារទាំងនោះទៅនឹងយុទ្ធនាការរបស់យើង។

**ផ្តោត**

សាររបស់យើងត្រូវតែផ្តោតទៅលើអង្គគោលដៅជាក់លាក់ ឬ ដោយគោរពចំណង់ចំណូលចិត្តរបស់អ្នកទទួល។ នេះមិនមែនមានន័យថា ជាការផ្លាស់ប្តូរន័យនៃសាររបស់យើងនោះទេ ប៉ុន្តែគឺជាការផ្លាស់ប្តូរនូវរបៀបបង្ហាញសារ។ សូមកុំប្រើប្រាស់ភាសាដែលនាំឱ្យខូចប្រយោជន៍ ឬ ដែលធ្វើឱ្យអាក់អន់ចិត្ត។

| សារដើម | សារដែលគេធ្វើអោយប្រសើរឡើង |
|---|---|
| "បញ្ឈប់ការរើសអើងប្រឆាំងនឹងមនុស្សពេញវ័យចំនួន ២,៦% នៅក្នុងប្រទេសកម្ពុជាដែលមានជម្ងឺអេដស៍។ | "ស្រមៃថា ប្រសិនបើមនុស្សគ្រប់រូបដែលនៅក្នុងក្រុងព្រះសីហនុមានផ្ទុកវីរុសហ៊ីវ ឬ ជំងឺអេដស៍។ យើងមិនអាចលៃលកការចំណាយខាងសេដ្ឋកិច្ចទៅលើការរើសអើងចំពោះមនុស្សចំនួនទាំង ១៧០.០០០នាក់ទេ។ |
| "កុមារ៣៥.០០០នាក់ស្លាប់ជារៀងរាល់ថ្ងៃបណ្តាលមកពីកង្វះអាហារូបត្ថម្ភ។ យើងត្រូវតែធ្វើការងារដើម្បីបញ្ឈប់វិបត្តិកង្វះអាហារូបត្ថមទូទាំងពិភពលោក។ | "យន្តហោះប្រតិកម្មធុនធំ ១០០គ្រឿង ដែលមានកុមារ ៣៥០នាក់ នៅលើនោះធ្លាក់ជារៀងរាល់ថ្ងៃ។ សូមជួយបញ្ឈប់វិបត្តិខ្វះអាហារូបត្ថម្ភ"។ * |

* from UNICEF's "**silent emergency**" campaign.

## ផ្លាកសញ្ញា តើយើងអាចបង្កើតផ្លាកសញ្ញាបែបណា ដើម្បីបញ្ជូនគំនិតរបស់យើងតាមរយៈចក្ខុវិញ្ញាណ ?

មិនមែនគ្រប់សារទាំងអស់សុទ្ធតែត្រូវបានប្រាស្រ័យទាក់ទងតាមរយៈភាសានោះទេ។ ការធ្វើផ្លាកសញ្ញាសម្រាប់យុទ្ធនាការតស៊ូមតិរបស់យើងដោយប្រើប្រាស់រូបភាពក្រាហ្វិក ដូចជានិមិត្តរូប និង រូបសញ្ញាអាចប្រាស្រ័យទាក់ទងយ៉ាងឆាប់រហ័ស និង ច្បាស់លាស់។ ដូចគ្នានិងភាសានៃសារតស៊ូមតិរបស់យើងដែរ ផ្លាកសញ្ញាត្រូវតែបានប្រើប្រាស់ម្តងហើយម្តងទៀត ដើម្បីអោយគេស្គាល់សារនោះ។







**សារតស៊ូមតិដែលបានជោគជ័យបំផុត ជំរុញចិត្តមនុស្សឱ្យធ្វើសកម្មភាព ។**

# ការបញ្ជូនសារតស៊ូមតិ

នៅពេលដែលយើងបានជ្រើសរើសខ្លឹមសារ ភាសា និង ផ្លាកសញ្ញាសម្រាប់សារចំបង និងសារគាំទ្រហើយ យើងចាំបាច់ត្រូវសម្រេចថាតើត្រូវបញ្ជូនសាររបស់យើងយ៉ាងដូចម្តេច?

គ្រប់សារទាំងអស់ត្រូវតែមានអ្នកនាំសារម្នាក់។ អ្នកនាំសារម្នាក់និយាយក្នុងនាមយុទ្ធនាការតស៊ូមតិរបស់យើង។ ជារឿយៗអ្នកនាំសារដ៏ល្អបំផុតសម្រាប់យុទ្ធនាការតស៊ូមតិរបស់យើង គឺជាអ្នកណាមួយដែលទទួលរងនូវផលប៉ះពាល់ពីបញ្ហាដោយផ្ទាល់។ តាមស្ថានភាពជាក់ស្តែង គុណភាពអ្នកនាំសារមិនដូចគ្នាទេ អ្នកនាំសារខ្លះមានភាពស័ក្តិសិទ្ធិជាងអ្នកឯទៀត។ ប្រសិនបើយើងចង់គ្រប់គ្រងសាររបស់យើងឱ្យបានល្អិតល្អន់ និង ទទួលបាននូវភាពគួរជឿនោះ យើងអាចជ្រើសរើសអ្នកតំណាងអង្គការមិនមែនរដ្ឋាភិបាលរបស់យើងឱ្យធ្វើជាអ្នកនាំសារ។ ប្រសិនបើយើងចង់បង្កើនការអំពាវនាវរបស់យើងដើម្បីពង្រីកចំនួនអ្នកទទួលសារ យើងអាចជ្រើសរើសអ្នកចម្រៀង ឬ តារាទូរទស្សន៍ដែលមានប្រជាប្រិយភាពសម្រាប់ធ្វើជាអ្នកនាំសាររបស់យើង។

**កំណត់សម្គាល់ ៖**
ប្រសិនជាយើងជ្រើសរើសអ្នកនាំសារម្នាក់ដែលល្បីល្បាញ ចាំបាច់ត្រូវគិតអំពីការជាប់ទាក់ទងផ្នែកនយោបាយរបស់គាត់។ ការជាប់ទាក់ទងនេះអាចមានឥទ្ធិពលលើការព្រមទទួលយកសារពីសំណាក់អង្គគោលដៅរបស់យើង។

## អ្នកនាំសារ



### អ្នកទទួលផល

សមាជិកនៃក្រុមដែលទទួលរងនូវផលប៉ះពាល់ (ដែលគេហៅថា "អ្នកទទួលផល") គឺជាអ្នកនាំសារល្អឥតខ្ចោះ ពីព្រោះពួកគេអាចផ្តល់នូវរឿងផ្ទាល់ខ្លួន និង ដំណើររឿងផ្ទាល់នៃបញ្ហា។




### បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល

បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល គឺជាអ្នកនាំសារដ៏សមរម្យ នៅពេលដែលយើងចង់បង្ហាញឱ្យឃើញពីភាពគួរឱ្យជឿបាន និង នៅពេលដែលយើងចង់ត្រួតពិនិត្យសារតស៊ូមតិរបស់យើងដោយប្រុងប្រយ័ត្ន។




### ទីងមោង

ទីងមោងគឺជាអ្នកនាំសារដ៏ល្អឥតខ្ចោះនៅពេលដែលយើងចង់ប្រាស្រ័យទាក់ទងជាមួយកុមារ ឬ ប្រសិនបើសាររបស់យើងទាក់ទងនិងបញ្ហាមួយដែលពិបាកដោះស្រាយខាងវប្បធម៌។

(រូបថត ៖ ស្រោមអនាម័យ Number one របស់អង្គការ PSI)



### ជនល្បីល្បាញ

ជនល្បីល្បាញគឺជាអ្នកនាំសារដ៏ល្អឥតខ្ចោះនៅពេលដែលយើងចង់ពង្រីកការផ្សព្វផ្សាយសាររបស់យើងឱ្យបានទូលំទូលាយ ឬ ចង់ផ្សព្វផ្សាយទៅកាន់ផ្នែកផ្សេងៗនៃសង្គម ។

(រូបថត ៖ នាយកុយ តារាកំប្លែងកម្ពុជាដ៏មានប្រជាប្រិយ ធ្វើតេស្តិ៍ឈាមដើម្បីគាំទ្រដល់ការយល់ដឹងពី HIV /AIDS)

គឺជាការទទួលខុសត្រូវរបស់យើងក្នុងការអប់រំអ្នកនាំសារអំពីរបៀប ពេលវេលា និង ទីកន្លែងដ៏ត្រឹមត្រូវក្នុងការផ្តល់សារតស៊ូមតិរបស់យើង។

## របៀប តើយើងនឹងផ្សព្វផ្សាយសាររបស់យើងដោយរបៀបណា ?

នៅពេលជ្រើសរើសរបៀបផ្សព្វផ្សាយសារតស៊ូមតិរបស់យើង យើងត្រូវតែក្រឡេកមើលទៅលើចំណង់ចំណូលចិត្តរបស់អង្គគោលដៅនៃយុទ្ធនាការតស៊ូមតិរបស់យើង។ វាជាការសំខាន់ក្នុងការប្រើប្រាស់ភាសា និង រូបភាពដែលអង្គគោលដៅរបស់យើងស្គាល់ និង យល់បាន។ ជាឧទាហរណ៍នៅពេលដែលប្រាស្រ័យទាក់ទងជាមួយមនុស្សពេញវ័យដែលមិនចេះអក្សរ ការផ្សព្វផ្សាយតាមវិទ្យុ ឬ សៀវភៅរូបភាព អាចជារបៀបនៃសារដ៏មានប្រសិទ្ធភាពបំផុត។ នៅពេលប្រាស្រ័យទាក់ទងជាមួយសមាជិករដ្ឋាភិបាល យើងចាំបាច់ត្រូវរៀបចំសេចក្តីអធិប្បាយសង្ខេបមួយដែលមើលទៅឃើញជាការរៀបចំរបស់យើងមានលក្ខណៈជាអ្នកមានកិរិយាខ្ពស់ (អានទំព័រទី ១៩)។

## ពេលវេលា និង ទីកន្លែង តើយើងគួរផ្សព្វផ្សាយសាររបស់យើងនៅពេលណា និង នៅកន្លែងណា ?

យើងគួរតែផ្សព្វផ្សាយសាររបស់យើងនៅពេលមួយ និង ទីកន្លែងណាមួយដែលសមស្របបំផុតទៅនឹងជីវិតនៃអង្គគោលដៅរបស់យើង។ ជាឧទាហរណ៍ ប្រសិនបើយើងចង់ប្រាស្រ័យទាក់ទងជាមួយកម្មកររោងចក្រ យើងគួរតែជួបពួកគេនៅខាងក្រៅទ្វាររបងរោងចក្រក្នុងម៉ោងបិទ ឬ ពេលផ្លាស់ប្តូរវេន។ ដើម្បីប្រាស្រ័យទាក់ទងជាមួយសមាជិករដ្ឋាភិបាល យើងគួរតែរៀបចំផែនការកិច្ចប្រជុំតទល់មុខគ្នានៅក្នុងការិយាល័យរបស់គេ ឬ នៅមណ្ឌលបោះឆ្នោត ដែលជាកន្លែងដែលយើងអាចមានការយកចិត្តទុកដាក់ពេញលេញពីពួកគេ (មើលទំព័រទី ១៩)។ កិច្ចប្រជុំទាំងនេះ គួរតែត្រូវបានកំណត់ក្នុងអំឡុងពេលមួយដ៏ស្ងប់ស្ងាត់ គឺពុំមែនក្នុងអំឡុងពេលនៃវិបត្តិនយោបាយដ៏ធ្ងន់ធ្ងរនោះទេ។

# ការយល់ដឹងអំពីអំណាចនៅក្នុងសង្គម

អំណាច គឺជាលទ្ធភាពក្នុងការត្រួតត្រា ឬ ដាក់ឥទ្ធិពលលើនរណាម្នាក់ ឬ អ្វីមួយ។ យើងចាំបាច់ត្រូវយល់ដឹងពីអំណាច ពីព្រោះយុទ្ធនាការតស៊ូមតិដែលជោគជ័យ គឺនាំទៅដល់ការផ្លាស់ប្តូរនានានូវទំនាក់ទំនងនៃអំណាចក្នុងសង្គម។

ផ្នែកទាំងបីនៃសង្គមគឺ រដ្ឋ វិស័យឯកជន និង សង្គមស៊ីវិល។ ផ្នែកទាំងបីចែករំលែកអំណាចគ្នា ទោះបីជាការបែងចែកនោះរមែងតែងតែមិនស្មើគ្នាយ៉ាងណាក៏ដោយ។



**រដ្ឋ :** រដ្ឋមានអង្គភាពសាធារណៈដែលកំពុងធ្វើការដើម្បីធ្វើឱ្យមានការរីកចម្រើននូវផលប្រយោជន៍សាធារណៈ។ **ប្រភពនៃអំណាច :** ច្បាប់។

**វិស័យឯកជន :** វិស័យឯកជនមាន បុគ្គល និង អង្គភាពឯកជនដែលកំពុងធ្វើការ ដើម្បីធ្វើឱ្យមានការរីកចម្រើននូវផលប្រយោជន៍ឯកជន។ **ប្រភពនៃអំណាច** គឺទឹកប្រាក់។

**សង្គមស៊ីវិល :** សង្គមស៊ីវិលមាន ពលរដ្ឋ និង អង្គការនានាដែលកំពុងធ្វើការជាមួយគ្នា ដើម្បីធ្វើឱ្យមានការរីកចម្រើននូវផលប្រយោជន៍សាធារណៈ។ អង្គការមិនមែនរដ្ឋាភិបាលមួយ គឺជាផ្នែកមួយនៃសង្គមស៊ីវិល។ តាមរយៈយុទ្ធនាការតស៊ូមតិ យើងកំពុងតែជួយកសាងនូវអំណាចនៃសង្គមស៊ីវិលនៅក្នុងអភិបាលកិច្ច។ **ប្រភពនៃអំណាច** គឺសហគមន៍។

ក្នុងនាមជាអ្នកតស៊ូមតិ យើងនឹងប្រើប្រាស់អំណាចដើម្បីធ្វើឱ្យមានឥទ្ធិពលទៅលើមនុស្សផ្សេងៗគ្នានៅក្នុងផ្នែកទាំងបីនៃសង្គមនេះ ក្នុងគោលបំណងធ្វើឱ្យពួកគេដោះស្រាយបញ្ហានានានៅក្នុងសហគមន៍របស់យើង។

## ការស្វែងរកអំណាច

មនុស្សគ្រប់រូបចង់ទទួលបាននូវអំណាច។ ការដឹងអំពីអ្វីដែលធ្វើឱ្យយើងទទួលបាននូវអំណាច វានឹងជួយឱ្យយើងអាចយល់ដឹងនូវរបៀបធ្វើឱ្យមានឥទ្ធិពលទៅលើមនុស្សដទៃទៀត។

នៅពេលយើងមានអារម្មណ៍ថា គេមិនគោរព ឯកោ ឬមួយក៏ថាបញ្ហាមួយហួសពីការគ្រប់គ្រងរបស់យើង ពេលនោះយើងអាចមានឱកាសក្នុងការទទួលបានមកវិញនូវអំណាច ប្រសិនបើយើងស្វែងរកមនុស្ស ឬ អង្គការដទៃ ហើយបង្កើតទំនាក់ទំនងជាមួយគេ នាំគ្នាដោះស្រាយបញ្ហានោះជាមួយគ្នា។



**អ្វីដែលធ្វើឱ្យយើងទទួលអារម្មណ៍ថា...**

| មានអំណាច ? | គ្មានអំណាច ? |
|---|---|
| មានការគ្រប់គ្រងលើគេ | ខ្វះខាតការគ្រប់គ្រង |
| ត្រូវបានគេគោរព | មិនត្រូវបានគេគោរព |
| ដោះស្រាយបញ្ហាលំបាកៗបាន | មិនមានលទ្ធភាពក្នុងការដោះស្រាយបញ្ហា |
| ធ្វើការជាមួយអ្នកដទៃ | មានអារម្មណ៍ឯកោ |
| ធ្វើឱ្យអ្នកដទៃខ្លបខ្លាចយើង | មានអារម្មណ៍ភ័យខ្លាច |
| មានអ្នកដទៃគាំទ្រយើង | ខ្វះខាតធនធាន |

# អំណាចតាមរយៈកំណែនសហគមន៍

កំណែនសហគមន៍សំដៅទៅលើការជួបជុំប្រមូលផ្តុំគ្នានៃមនុស្សដើម្បីធ្វើសកម្មភាពរួមគ្នា។ ក្ងួដកម្ម ការដើរជាក្បួន ការតវ៉ាទាមទារ វេទិកា និង ការជួបប្រជុំគ្នា គឺជាទម្រង់ទូទៅមួយចំនួននៃកំណែនសហគមន៍។ អង្គការមិនមែនរដ្ឋាភិបាលជួយសហគមន៍ឱ្យរួបរួមគ្នាឡើងដើម្បីប្រែក្លាយអារម្មណ៍ដែលថាគ្មានអំណាចឱ្យទៅជាអារម្មណ៍នៃការមានអំណាច។

**កំណត់សម្គាល់ :**

ការសរសេរសាររបស់យើងនៅលើផ្ទាំងក្រដាសបដា។ល។ គេហៅថា "ការបង្កើននូវការយល់ដឹង"។ "កំណែនសហគមន៍" ទាមទារនូវសកម្មភាពដូចនេះរបស់ប្រជាពលរដ្ឋ។




## ប្រាំមួយជំហានសម្រាប់ការតវ៉ាដ៏ជោគជ័យមួយ

១. បង្កើតសារដែលបញ្ជាក់ច្បាស់លាស់អំពីបញ្ហាដែលយើងកំពុងតវ៉ា

២. ជូនដំណឹងដល់អាជ្ញាធរ អំពីការតវ៉ានេះ និង ការទទួលការអនុញ្ញាតដោយស្របច្បាប់។

៣. អញ្ជើញមិត្តភក្តិ អ្នកគាំទ្រជ្រោមជ្រែង និង សម្ព័ន្ធមិត្តរបស់យើងឱ្យចូលរួម ហើយត្រូវប្រាកដក្នុងចិត្តថាពួកគេនឹងមានវត្តមានជាមួយយើង។

៤. កំណត់ពេលវេលាដើម្បីចាប់ផ្តើម និង បញ្ចប់ការតវ៉ានេះ។ ជ្រើសរើសផ្លូវដើរឱ្យច្បាស់លាស់សម្រាប់អ្នកតវ៉ា។

៥. ទាក់ទាញការយកចិត្តទុកដាក់របស់ហ្វូងមនុស្ស និង ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដោយមានផ្លាកសញ្ញា ការសូត្រធម៌ ចម្រៀង និង ការកំសាន្ត

៦. មានផែនការសន្តិសុខ ដើម្បីធានាឱ្យប្រាកដថា អ្នកចូលរួមនឹងមានសុវត្ថិភាព និង ពោរពេញដោយសន្តិភាព។

# អំណាចរដ្ឋាភិបាល

ដើម្បីប្រើប្រាស់អំណាចរបស់យើងក្នុងការបញ្ចុះបញ្ចូលសមាជិករដ្ឋាភិបាល យើងត្រូវស្វែងយល់រចនាសម្ព័ន្ធរដ្ឋាភិបាល និងដំណើរការ ធ្វើច្បាប់។ កម្ពុជាជាប្រទេសប្រជាធិបតេយ្យ រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ នេះមានន័យថា ព្រះមហាក្សត្រទ្រង់ស្ថិតជាកំពូលលើស្ថាប័នបីសំខាន់ៗ គឺ គណៈរដ្ឋមន្ត្រី រដ្ឋសភា និង ព្រឹទ្ធសភា។

## រចនាសម្ព័ន្ធគ្រប់គ្រងនៃ កម្ពុជា



## ប្រជាធិបតេយ្យជាអ្វី ?

ប្រជាធិបតេយ្យ គឺជាប្រព័ន្ធអភិបាលកិច្ចមួយដែលប្រជាពលរដ្ឋ មានសិទ្ធិដោយផ្ទាល់ ឬ តាមរយៈអ្នកតំណាងរាស្ត្រដែលជាប់ឆ្នោត ប្រជាពលរដ្ឋមានសិទ្ធិ និង អំណាច ក្នុងការផ្លាស់ប្តូរគោលនយោបាយ ឬ ការប្រតិបត្តិ ដើម្បីធ្វើឱ្យសង្គមមានភាពប្រសើរឡើង។

នៅក្នុងលទ្ធិប្រជាធិបតេយ្យ សមាជិកនៃសង្គមស៊ីវិលមានសិទ្ធិ និង ករណីយកិច្ចក្នុងការជម្រាបប្រាប់មន្ត្រីរដ្ឋាភិបាលថាតើរដ្ឋាភិបាលកំពុងបំពេញមុខងារយ៉ាងណានោះ។ គឺជាតួនាទីនៃសង្គមស៊ីវិលក្នុងការជំរុញឱ្យមានដំណើរការធ្វើច្បាប់ និង ការបោះឆ្នោតដ៏ត្រឹមត្រូវ ហើយត្រួតពិនិត្យតាមដានផ្នែកទាំងពីរឱ្យបានដិតដល់។

### នីតិប្រតិបត្តិ

"**ព្រះមហាក្សត្រ** ទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត"។ "ព្រះមហាក្សត្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ"។

មុខងារចម្បងរបស់**ក្រុមប្រឹក្សារាជសម្បត្តិ** គឺជ្រើសរើសព្រះមហាក្សត្រសម្រាប់គ្រងរាជសម្បត្តិ ពីព្រោះមិនដូចរបបរាជានិយមដទៃទៀតទេដែលខ្សែស្រឡាយរាជវង្សអាចឡើងគ្រងរាជ្យដោយស្វ័យប្រវត្តិចាប់ពីព្រះរាជបុត្រច្បង របស់ព្រះមហាក្សត្រនោះ។ ក្រុមប្រឹក្សានេះមាន សម្តេចព្រះសង្ឃរាជទាំងពីរគណៈ និង អ្នកនយោបាយលំដាប់ ខ្ពស់បំផុតចំនួន ៧រូប។

មុខងារចម្បងរបស់**គណៈរដ្ឋមន្ត្រី** ដែលគេហៅថារាជរដ្ឋាភិបាលកម្ពុជាផងដែរនោះ គឺប្រតិបត្តិច្បាប់ និង គោលនយោបាយ ដែលនឹងគ្រប់គ្រងប្រទេសកម្ពុជា។ សមាជិកគណៈរដ្ឋមន្ត្រីមាន នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួងនីមួយៗ និង រដ្ឋលេខាធិការ។




### នីតិបញ្ញត្តិ

មុខងារចម្បងរបស់**រដ្ឋសភា** គឺអនុម័តច្បាប់ ដែលនឹងគ្រប់គ្រងប្រទេសកម្ពុជា ហើយបោះឆ្នោតជ្រើសរើសនាយករដ្ឋមន្ត្រី។ សមាជិករដ្ឋសភាត្រូវបានបោះឆ្នោតជ្រើសតាំងដោយប្រជាពលរដ្ឋខ្មែរ ហើយមានអាណត្តិ ៥ឆ្នាំ ។

**គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា** មានមុខងារចម្បងក្នុងការរៀបចំរបៀបវារៈប្រជុំពេញអង្គនៃរដ្ឋសភា។ គណៈកម្មាធិការនេះមាន ប្រធាននៃគណៈកម្មការនីមួយៗនៃរដ្ឋសភាផងដែរជាសមាជិក។

តួនាទីចម្បងរបស់ព្រឹទ្ធសភា គឺដើម្បីពិនិត្យមើលឡើងវិញនូវច្បាប់ទាំងឡាយដែលបានអនុម័តដោយរដ្ឋសភា និង អាចស្នើច្បាប់បានដែរ។ សមាជិកទាំងឡាយរបស់ព្រឹទ្ធសភាភាគច្រើន ត្រូវបានជ្រើសតាំងដោយការបោះឆ្នោតអសកល។

គណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា មានតួនាទីចម្បងគឺស្នើរបៀបវារៈប្រជុំពេញអង្គនៃព្រឹទ្ធសភា។ គណៈកម្មាធិការនេះមានប្រធានគណៈកម្មការនីមួយៗចូលរួមជាសមាជិកផងដែរ។




### តុលាការ

**តុលាការកំពូល** គឺជាតុលាការថ្នាក់ខ្ពស់បំផុតនៅក្នុងប្រទេស ហើយយុត្តាធិការរបស់ស្ថាប័ននេះគ្របដណ្តប់ទៅលើដែនដីនៃប្រទេសកម្ពុជាទាំងមូល។

**សាលាឧទ្ធរណ៍** ចាំទទួលគ្រប់ករណីទាំងអស់ដែលគេសើរើប្តឹងជាថ្មីទៀតពីតុលាការខេត្តក្រុង និង តុលាការយោធា។

មុខងារចម្បងរបស់**ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** គឺធានាការប្រព្រឹត្តទៅនៃតុលាការ។ សមាជិកទាំង ៩ រូបរបស់ស្ថាប័ននេះមាន :

- -ព្រះមហាក្សត្រ
- -រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
- -ប្រធានតុលាការកំពូល
- -អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល
- -ប្រធានសាលាឧទ្ធរណ៍
- -អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
- -ចៅក្រមបីរូបដែលជ្រើសតាំងដោយចៅក្រមខ្លួនឯងផ្ទាល់។

មុខងារចម្បងរបស់**ក្រុមប្រឹក្សាធម្មនុញ្ញ**គឺកំណត់នូវធម្មនុញ្ញភាពនៃច្បាប់ និងមានសិទ្ធិពិនិត្យ និងសម្រេចអំពីករណីវិវាទកម្មទាក់ទងនឹងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា។ សមាជិកទាំង ៩ ត្រូវបានជ្រើសតាំង៣រូបដោយព្រះមហាក្សត្រ ៣រូបដោយរដ្ឋសភា និង ៣រូបដោយឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម។

# ដំណើរការធ្វើច្បាប់

ដំណើរការធ្វើច្បាប់ នឹងពណ៌នាថាតើសំណើនៃពង្រាងច្បាប់មួយ អាចក្លាយទៅជាច្បាប់បានដោយរបៀបណា។ ប្រទេសនីមួយៗដែលកាន់លទ្ធិប្រជាធិបតេយ្យ មានដំណើរការធ្វើច្បាប់របស់គេរៀងៗខ្លួន។ ឧបមាថា យើងចង់អនុម័តច្បាប់ស្តីអំពីកំណែទម្រង់ដីធ្លីនៅក្នុងប្រទេសកម្ពុជា។ នេះគឺជាដំណើរការធ្វើច្បាប់៖




**១**

សមាជិកមួយរូបនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ដាក់ជូននូវពង្រាងច្បាប់កំណែទម្រង់ដីធ្លីទៅកាន់ក្រុមការងារនីតិកម្មរបស់ក្រសួងសម្រាប់ពិនិត្យ និង ពិចារណា។

**២**

ក្រុមការងារនីតិកម្មនៅក្នុងក្រសួង នឹងពិនិត្យមើល ហើយកែសម្រួលនូវពង្រាងច្បាប់នោះ។ គេនឹងស្នើសុំការចូលរួមចំណែកបន្ថែមទៀតពីក្រុមប្រឹក្សាអ្នកច្បាប់។

**៣**

ក្រុមប្រឹក្សាអ្នកច្បាប់ ពិនិត្យមើលពង្រាងច្បាប់នេះ ហើយពិគ្រោះយោបល់ជាមួយក្រុមការងារនីតិកម្ម ដើម្បីបញ្ជាក់ឱ្យច្បាស់លាស់អំពីបញ្ហាច្បាប់ ដែលពាក់ព័ន្ធនិងច្បាប់នេះ។ នៅពេលចប់រួចរាល់ហើយ ទើបគេដាក់ជូនទៅគណៈកម្មា-ធិការអន្តរក្រសួង ដើម្បីសុំឱ្យពិនិត្យ។

**៤**

ក្រុមការងារអន្តរក្រសួងនឹងពិនិត្យមើល ហើយកែសម្រួលពង្រាងច្បាប់នេះមុននឹងបញ្ជូនទៅគណៈរដ្ឋមន្ត្រី។

**៥**

គណៈរដ្ឋមន្ត្រី ពិនិត្យសារឡើងវិញនូវសេចក្តីព្រាងច្បាប់នេះ។ បើមានការយល់ព្រម នាយករដ្ឋមន្ត្រីដាក់ជូនច្បាប់នេះ និង សេចក្តីថ្លែងហេតុ ទៅកាន់ប្រធាន រដ្ឋសភា។

**៦**

ប្រធានរដ្ឋសភា ប្រគល់សេចក្តីព្រាងច្បាប់ និង សេចក្តីថ្លែងហេតុទៅឱ្យគណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា។

**៧**

គណៈកម្មាធិការអចិន្ត្រៃយ៍ ពិនិត្យឡើងវិញនូវសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់ រួចហើយ បញ្ជូនបន្តទៅឱ្យគណៈកម្មការជំនាញ។

សង្គមស៊ីវិលដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រយុទ្ធប្រឆាំងនឹងអយុត្តិធម៌ និង វិសមភាព ដោយប្រើប្រាស់ដំណើរការធ្វើច្បាប់តាមមធ្យោបាយគន្លឹះពីរយ៉ាងគឺ ៖

**ការធ្វើពង្រាងច្បាប់** និង **ការបញ្ចុះបញ្ចូល**មន្ត្រីរដ្ឋាភិបាល។

# របៀបដែលសេចក្តីព្រាងច្បាប់ក្លាយទៅជាច្បាប់នៅក្នុងប្រទេស **កម្ពុជា**



**៩**

ប្រសិនបើរដ្ឋសភាបានអនុម័តរួច ហើយ ប្រធានរដ្ឋសភាប្រគល់សេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់នេះជូនទៅប្រធានព្រឹទ្ធសភា។

**១១**

គណៈកម្មាធិការអចិន្ត្រៃយ៍ ពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់រួចហើយ បញ្ជូនបន្តទៅឱ្យគណៈកម្មការជំនាញ។

**១៣**

ព្រឹទ្ធសភា និង រដ្ឋសភា បញ្ជូនសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់ បង្វិលទៅបង្វិលមក ដើម្បីធ្វើការកែប្រែចុងក្រោយនៃសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់នេះ។ ប្រសិនបើព្រឹទ្ធសភា និង រដ្ឋសភា អនុម័តរួចហើយ ប្រធានរដ្ឋសភាថ្វាយសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់នេះចំពោះព្រះមហាក្សត្រ។

**១៥**

ព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យប្រែក្លាយសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់នេះឱ្យទៅជាច្បាប់ពិតប្រាកដមួយ។




**៨**

គណៈកម្មការជំនាញពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ រួចហើយ :

១. ផ្តល់អនុសាសន៍ដល់អង្គសភាទាំងមូលមិនឱ្យយកមកពិនិត្យពិចារណា ឬមួយក៏

២. ស្នើសុំដល់អង្គសភាទាំងមូលឱ្យយកមកពិភាក្សាអនុម័ត ឬមួយក៏

៣. ស្នើសុំដល់អង្គសភាលើកយកមកពិភាក្សាអនុម័ត និងចាត់ទុកថាជាការប្រញាប់។

**១០**

ប្រធានព្រឹទ្ធសភាប្រគល់សេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់នេះជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភា។

**១២**

គណៈកម្មការជំនាញពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់រួចហើយ :

១. ផ្តល់អនុសាសន៍ដល់អង្គសភាទាំងមូលមិនឱ្យយកមកពិនិត្យពិចារណា ឬមួយក៏

២. ស្នើសុំដល់អង្គសភាទាំងមូលឱ្យយកមកពិភាក្សាអនុម័ត ឬមួយក៏

៣. ស្នើសុំដល់អង្គសភាលើកយកមកពិភាក្សាអនុម័ត និង ចាត់ទុកថាជាការប្រញាប់។

**១៤**

ក្រុមប្រឹក្សាធម្មនុញ្ញ មានអំណាចក្នុងការបកស្រាយថាតើច្បាប់ដែលអនុម័តដោយរដ្ឋសភា និង ដែលពិនិត្យពេញលេញឡើងវិញដោយព្រឹទ្ធសភានោះ មានធម្មនុញ្ញភាពដែរឬទេ ?

ច្បាប់ដែលប្រកបដោយប្រសិទ្ធភាព គឺផ្លាស់ប្តូរឥរិយាបថរបស់ប្រជាពលរដ្ឋ និង មានផលប៉ះពាល់ពិតប្រាកដលើជីវិតរស់នៅរបស់ប្រជាពលរដ្ឋ។ ច្បាប់មួយ ឬ កង្វះខាតច្បាប់ អាចបណ្តាលឱ្យមានអយុត្តិធម៌ និង វិសមភាពតាមរបៀបបីយ៉ាង គឺ :

## ពាក្យពេចន៍

ច្បាប់ ឬ គោលនយោបាយ បដិសេធយ៉ាងជាក់លាក់ចំពោះសិទ្ធិជាមូលដ្ឋាន ឬ មានលក្ខណៈជាការរើសអើង។

**ឧទាហរណ៍** : ស្ត្រីមិនត្រូវបានអនុញ្ញាតឱ្យបោះឆ្នោតទេ។

## ឥរិយាបថ

ច្បាប់ ឬ គោលនយោបាយ មិនត្រូវបានគេប្រតិបត្តិ ឬ ត្រូវបានអនុវត្តក្នុងលក្ខណៈលំអៀង មិនត្រឹមត្រូវទៅរកមនុស្សមួយចំនួនលើសពីមនុស្សមួយចំនួនផ្សេងទៀត។

**ឧទាហរណ៍** : មនុស្សគ្រប់រូប ត្រូវតែបង់ពន្ធ លើកលែងតែមន្ត្រីរដ្ឋាភិបាល។

## ទំនៀមទម្លាប់

សាធារណជនអាចមិនយល់ដឹងអំពីច្បាប់ ឬ ទំនៀមទម្លាប់ប្រពៃណី និង ទម្លាប់ជាទូទៅដែលធ្វើឱ្យពិបាកក្នុងការពង្រឹងច្បាប់។

**ឧទាហរណ៍** : គ្រួសារជនរងគ្រោះមិនព្រមសហការជាមួយព្រះរាជអាជ្ញា តែបែរជាព្រមទទួលយកសំណងពីឧក្រិដ្ឋជនទៅវិញ។

# ការព្រាងច្បាប់

ការព្រាងច្បាប់ តម្រូវឱ្យយើងកំណត់ជាបឋមនូវឥរិយាបថរបស់អ្នកដែលកំពុងធ្វើឱ្យមានបញ្ហា។ យើងអាចចាប់ផ្តើមធ្វើបញ្ជីមនុស្សទាំងអស់ដែលពាក់ព័ន្ធទៅនឹងការបង្កើតបញ្ហា។ សំណួរដ៏សំខាន់បំផុតក្នុងការសួរខ្លួនយើងនោះគឺ "តើឥរិយាបថរបស់អ្នកណាដែលចាំបាច់ត្រូវផ្លាស់ប្តូរ ដើម្បីឱ្យបញ្ហាឈានដល់ទីបញ្ចប់ ?"។

ជាឧទាហរណ៍ ច្បាប់ស្តីអំពីអំពើហឹង្សាក្នុងគ្រួសារ អាចធ្វើឡើងដើម្បីដាក់ទណ្ឌកម្មចំពោះ ជនល្មើស។ ប៉ុន្តែ យើងត្រូវតែពិនិត្យមើលផងដែរថាតើឥរិយាបថរបស់ នគរបាល ចៅក្រម មន្ត្រីរដ្ឋាភិបាល ព្រះរាជអាជ្ញា មន្ទីរពេទ្យ ឬ អ្នកឯទៀតដែលអាចចូលពាក់ព័ន្ធនឹងបញ្ហាត្រូវធ្វើការផ្លាស់ប្តូរបានយ៉ាងដូចម្តេច។

ក្រោយពីយើងបានកំណត់ពីឥរិយាបថរបស់អ្នកណាដែលយើងចាំបាច់ត្រូវផ្លាស់ប្តូររួចហើយ បន្ទាប់មកយើងអាចស្វែងរកនូវរាល់ដំណោះស្រាយតាមការធ្វើច្បាប់ដែលអាចមាន។ ត្រូវចាប់ផ្តើមឡើងដោយការស្រាវជ្រាវអំពីច្បាប់ ពង្រាងច្បាប់ និង របាយការណ៍ទាំងអស់ដែលពាក់ព័ន្ធ។ ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ជាតិ ថ្នាក់តំបន់ និង ថ្នាក់មូលដ្ឋាន គឺជាធនធានជាក់ស្តែងសម្រាប់ជាព័ត៌មាន។ ខាងក្រោមនេះគឺជាប្រភពមួយចំនួននៃព័ត៌មាន :

## ប្រភពសម្រាប់ការស្រាវជ្រាវនីតិកម្ម

| | | |
|---|---|---|
| **សាកលវិទ្យាល័យ<br>វិទ្យាស្ថានស្រាវជ្រាវ<br>បណ្ណាល័យ** | **ទិនានុប្បវត្តិច្បាប់<br>អត្ថបទផ្សាយ<br>អង្គការមិនមែនរដ្ឋាភិបាលដទៃទៀត** | **អ្នកសារព័ត៌មាន<br>ម្ចាស់ជំនួយអន្តរជាតិ<br>អ៊ិនធើរណេត** |

នៅពេលធ្វើការស្រាវជ្រាវអំពីនីតិកម្ម ជារឿយៗមានប្រយោជន៍ផងដែរក្នុងការក្រឡេកមើលទៅរដ្ឋាភិបាលប្រទេសដទៃទៀតដើម្បីទទួលបាននូវទស្សនៈវិស័យ ជាលក្ខណៈអន្តរជាតិនៃបញ្ហា។ រដ្ឋាភិបាលប្រទេសដទៃទៀតអាចនឹងមានបទពិសោធន៍ និង ជំនាញច្រើនជាងចំពោះបញ្ហានោះ ហើយដែលជាហេតុនាំឱ្យអាចនឹងមានការប្រតិបត្តិល្អបំផុតជាលក្ខណៈអន្តរជាតិ ដែលមានបញ្ចូលរួចជាស្រេចនៅក្នុងនីតិកម្មរបស់គេ។ ក៏ប៉ុន្តែទោះបីជាប្រទេសដទៃទៀត អាចនឹងអនុវត្តរួចហើយនូវដំណោះស្រាយតាមរយៈការធ្វើច្បាប់លើបញ្ហាមួយដូចបញ្ហារបស់យើងយ៉ាងណាក៏ដោយ ក៏យើងត្រូវធ្វើការកត់សំគាល់ថាច្បាប់ និង វប្បធម៌មានឥទ្ធិពលលើគ្នាទៅវិញទៅមក។ អ្វីដែលបម្រើមនុស្សមួយក្រុម ឬ សង្គមមួយ អាចនឹងមិនបម្រើមនុស្សមួយក្រុម ឬ សង្គមមួយផ្សេងទៀតឡើយ។ ការងារនីតិកម្មរបស់យើង មិនមែនមានត្រឹមតែជាការចម្លងតាមច្បាប់នៃប្រទេសដទៃនោះទេ តែត្រូវឆ្លុះបញ្ចាំងពីសេចក្តីត្រូវការរបស់សហគមន៍យើង។

មធ្យោបាយល្អបំផុតក្នុងការស្វែងរកឱ្យឃើញពីសេចក្តីត្រូវការរបស់សហគមន៍យើង គឺសួរទៅគេ! ឧទាហរណ៍ ដូចជាថាតើមានការព្រមព្រៀងមតិគ្នានៅក្នុងសហគមន៍ និង ក្នុងចំណោមសាធារណជនដែរឬទេដែលថាចាំបាច់ត្រូវផ្លាស់ប្តូរច្បាប់នោះ ? តើសេចក្តីស្នើផ្លាស់ប្តូរច្បាប់របស់យើងអាចនឹងជះឥទ្ធិពលយ៉ាងដូចម្តេចខ្លះទៅលើផ្នែកផ្សេងៗនៃសង្គម ? វិធីស្រាវជ្រាវជាច្រើនមានដូចជាការស្ទាបស្ទង់មតិសម្ភាសន៍ ការពិនិត្យសង្កេតជាដើម ដែលអាចប្រើប្រាស់បានដើម្បីជួយអប់រំយើងអំពីរបៀបដែលប្រជាពលរដ្ឋយល់ដឹងពីច្បាប់បច្ចុប្បន្នយ៉ាងដូចម្តេច និង អំពីសំណើដំណោះស្រាយរបស់យើង។

នៅពេលដែលយើងបានធ្វើការស៊ើបអង្កេតសព្វគ្រប់ទៅលើជម្រើសទាំងអស់ដែលអាចមាន យើងអាចចាប់ផ្តើមបង្កើតនូវដំណោះស្រាយនីតិកម្មរបស់យើងផ្ទាល់បាន។ យើងត្រូវតែធ្វើឱ្យអ្នកពាក់ព័ន្ធសំខាន់ៗ អ្នកនយោបាយ និង សមាជិកគណបក្សនយោបាយ ជាប់ទាក់ទងទៅនឹងដំណើរការនេះដើម្បីបញ្ចូលនូវគំនិតរបស់ពួកគេ និង ទទួលបាននូវការគាំទ្រពីពួកគេ។ ពង្រាងច្បាប់របស់យើង មិនចាំបាច់ល្អឥតខ្ចោះនោះទេ។ វានឹងត្រូវបានកែបន្ថែមបន្ថយដោយអ្នកច្បាប់ និង ទីប្រឹក្សាច្បាប់ដែលមានបទពិសោធន៍ច្រើននៅក្នុងដំណើរការធ្វើច្បាប់នេះ។

**កំណត់សម្គាល់ :**

នៅពេលយើងធ្វើការស្រាវជ្រាវ យើងត្រូវតែគិតពិចារណាអំពីភាពគួរធ្វើបាន និង ភាពត្រឹមត្រូវនៃព័ត៌មានដែលយើងរកបាន។ ភាពគួរជឿជាក់ទៅលើសេចក្តីព្រាងច្បាប់របស់យើង នឹងអាស្រ័យលើការស្រាវជ្រាវហ្មត់ចត់ ការវិភាគ គោលបំណង និង ការផ្តល់ឯកសារសមស្រប។

នៅពេលដែលពង្រាងច្បាប់កំពុងឆ្លងកាត់ដំណើរការធ្វើច្បាប់នោះវាសំខាន់ណាស់សម្រាប់យើងក្នុងការតាមដានដំណើរវិវឌ្ឍន៍នៃពង្រាងច្បាប់របស់យើងដើម្បីធ្វើឱ្យប្រាកដថាមានការផ្លាស់ប្តូរ ឬកែប្រែអ្វីដែលគាំទ្រគោលបំណងរួមខាងដើមរបស់យើង។ បើការផ្លាស់ប្តូរពង្រាងច្បាប់មានច្រើនហួសពេកយើងអាចដកការគាំទ្ររបស់យើងចំពោះច្បាប់នេះ។ យើងអាចជំរុញដំណើរការវិវឌ្ឍន៍នៃសេចក្តីព្រាងច្បាប់របស់ យើងតាមរយៈការបញ្ចុះបញ្ចូលអ្នកធ្វើសេចក្តីសម្រេចដ៏សំខាន់នៅក្នុងជួររដ្ឋាភិបាល។

# ការបញ្ចុះបញ្ចូល

ការបញ្ចុះបញ្ចូល គឺជាសិល្បៈនៃការអន្ទងមន្ត្រីសាធារណៈឱ្យគាំទ្រ ឬ ប្រឆាំងនឹងច្បាប់មួយ និង ការដាក់ឱ្យប្រតិបត្តិនូវច្បាប់នោះ។ នៅក្នុងយុទ្ធនាការតស៊ូមតិ ដែលស្វែងរកការផ្លាស់ប្តូរច្បាប់ ការបញ្ចុះបញ្ចូល គឺជាផ្នែកមួយដ៏សំខាន់នៃសកម្មភាពតស៊ូមតិរបស់យើង។

## តើខ្ញុំបញ្ចុះបញ្ចូលយ៉ាងដូចម្តេចដើម្បីឱ្យមានប្រសិទ្ធភាព ?

ដើម្បីបញ្ចុះបញ្ចូលមន្ត្រីរដ្ឋាភិបាល យើងត្រូវតែរៀបចំឯកសាររបស់យើង និង អ្នកនាំសារដោយយកចិត្តទុកដាក់។ យើងត្រូវតែកំណត់ផងដែរនូវអ្នកច្បាប់ផ្សេងៗគ្នាដែលមានមុខតំណែងខ្ពស់ៗ។

គេបែងចែកអ្នកនីតិបញ្ញត្តិជាប្រាំប្រភេទ។ ប្រភេទនីមួយៗតម្រូវឱ្យមានយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងផ្សេងៗគ្នា :

**កំណត់សម្គាល់ :**

ជូនកាលអ្នកតស៊ូមតិ មានការភ័ន្តច្រឡំនូវពាក្យ "បញ្ចុះបញ្ចូល" និង "ការតស៊ូមតិ"។ យុទ្ធនាការតស៊ូមតិដែលជោគជ័យ ប្រើប្រាស់នូវសកម្មភាពជាច្រើនដូចជា សិក្ខាសាលា បាតុកម្ម ការដើរក្បួន និង ជួបប្រជុំជាមួយមន្ត្រីរដ្ឋាភិបាល ដើម្បីសម្រេចបាននូវគោលដៅតស៊ូមតិ។ បើគ្រាន់តែជួបប្រជុំជាមួយមន្ត្រីរដ្ឋាភិបាល គេហៅថាការបញ្ចុះបញ្ចូល។ ការបញ្ចុះបញ្ចូល គឺគ្រាន់តែជាវិធីសាស្ត្រមួយប៉ុណ្ណោះ ដែលយើងនឹងប្រើប្រាស់ដើម្បីសម្រេចនូវគោលដៅតស៊ូមតិរបស់យើង។

### អ្នកនីតិបញ្ញត្តិប្រាំប្រភេទ

| ប្រភេទ | ការពណ៌នា | យុទ្ធសាស្ត្រប្រាស្រ័យទាក់ទង |
|---|---|---|
|  អ្នកគាំទ្រជើងឯក Champion | **អ្នកគាំទ្រជើងឯក** : គឺជាអ្នកនីតិបញ្ញត្តិដែលមានជំនឿទៅលើយុទ្ធនាការតស៊ូមតិរបស់យើង ហើយគាំទ្រយ៉ាងសកម្ម។ ពួកគេនឹងផ្តល់សារតស៊ូមតិរបស់យើងទៅឱ្យអ្នកបញ្ញត្តិច្បាប់ដទៃទៀត ហើយគឺជាអ្នកនាំពាក្យដែលអាចមើលឃើញសម្រាប់យុទ្ធនាការនេះ។ | ផ្តល់ដល់**អ្នកគាំទ្រជើងឯក**នូវព័ត៌មានដែលគួរជឿបានដែលពួកគេអាចប្រើប្រាស់ដើម្បីធ្វើឱ្យអ្នកបញ្ញត្តិច្បាប់ដទៃទៀតជឿក្នុងការចូលរួមក្នុងបុព្វហេតុរបស់យើង។ |
|  មិត្ត Friend | **មិត្ត** : គឺជាអ្នកបញ្ញត្តិច្បាប់ដែលគាំទ្រយុទ្ធនាការតស៊ូមតិរបស់យើង ប៉ុន្តែមិនទាន់បានចូលរួម ឬ រួមចំណែកឱ្យបានច្រើនណាស់ណានៅឡើយទេ។ | ព្យាយាមធ្វើឱ្យ**មិត្ត**ជឿក្នុងការចូលពាក់ព័ន្ធថែមទៀតក្នុងយុទ្ធនាការរបស់យើង។ |
|  អ្នកកណ្តាល Fence-Sitter | **អ្នកកណ្តាល** : គឺជាអ្នកបញ្ញត្តិច្បាប់ដែលអព្យាក្រឹតផងមិនស៊ូប្តូរចំពោះ ខាងណាមួយនៅឡើយទេ។ | **អ្នកកណ្តាល** គឺជាអង្គគោលដៅដ៏ចម្បងនៃកិច្ចប្រឹងប្រែងបញ្ចុះបញ្ចូលរបស់យើង។ យើងចាំបាច់ត្រូវប្រើប្រាស់មិត្ត និង អ្នកគាំទ្រជើងឯករបស់យើង ដើម្បីធ្វើឱ្យពួកគេចូលមកគាំទ្រខាងយើង។ |
|  អ្នកមិនគាំទ្រ Opponent | **អ្នកមិនគាំទ្រ** : គឺជាអ្នកបញ្ញត្តិច្បាប់ដែលនឹងបោះឆ្នោតមិនគាំទ្រយើងយ៉ាងច្បាស់លាស់ ប៉ុន្តែពុំមានពេលវេលា ធនធាន ឬ បំណងប្រាថ្នាធ្វើការប្រឆាំងយើងទេ។ | ព្យាយាមរារាំង**អ្នកមិនគាំទ្រ**យុទ្ធនាការតស៊ូមតិរបស់យើងមិនឱ្យមានលក្ខណៈកាន់តែសកម្ម និង បញ្ចេញយោបល់ដោយឥតសំចៃ។ |
|  សត្រូវ Enemy | **សត្រូវ** : គឺជាអ្នកដែលប្រឆាំងយ៉ាងសកម្មទៅនឹងគោលដៅតស៊ូមតិរបស់យើង។ | យើងត្រូវតែផ្តល់មូលហេតុច្បាស់លាស់ថាតើហេតុអ្វីបានជាអ្នកបញ្ញត្តិច្បាប់ដទៃទៀតមិនត្រូវចូលរួមជាមួយ**សត្រូវ**របស់យើង។ |

## តើអ្នកណាខ្លះដែលជាអ្នកគាំទ្រជើងឯក និង ជាមិត្តរបស់យើងនៅក្នុងរដ្ឋាភិបាល ?

# ការបញ្ចុះបញ្ចូល

បណ្តាយុទ្ធសាស្ត្រប្រាស្រ័យទាក់ទងនីមួយៗ ត្រូវប្រើប្រាស់នៅក្នុងសកម្មភាពបញ្ចុះបញ្ចូលរបស់យើង។ តារាងខាងក្រោមនេះពណ៌នាអំពីចំណុចផ្សេងៗគ្នានៅក្នុងដំណើរការធ្វើច្បាប់ នៅពេលដែលសមាជិកនៃរដ្ឋាភិបាលទំនងជាមិនស្តាប់ទស្សនៈរបស់យើងលើពង្រាងច្បាប់។

**បញ្ចុះបញ្ចូលនៅទីនេះ !**

បុគ្គលិកនៃក្រសួង ចាប់ផ្តើមព្រាងច្បាប់។ ក្រសួងអាចបើកចំហនូវដំណើរការធ្វើច្បាប់ជូនចំពោះសង្គមស៊ីវិលតាមរយៈសិក្ខាសាលា វេទិកា និង កិច្ចពិភាក្សា ជាសាធារណៈ។

**បញ្ចុះបញ្ចូលនៅទីនេះ !**

នាយករដ្ឋមន្ត្រី គឺជាមនុស្សដែលមានអំណាចបំផុតនៅក្នុងជួររដ្ឋាភិបាល។ ប្រសិនបើយើងអាចធ្វើឱ្យនាយករដ្ឋមន្ត្រីជឿថា ពង្រាងច្បាប់របស់យើងមានសារៈសំខាន់នោះ ជារឿយៗ សមាជិកនៃរដ្ឋាភិបាលតែងធ្វើតាម។




**បញ្ចុះបញ្ចូលនៅទីនេះ !**

គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា និង គណៈកម្មការជំនាញណាមួយនៃរដ្ឋសភា អាចផ្តួចផ្តើមគំនិតឱ្យមានដំណើរការធ្វើច្បាប់ផងដែរ។ ដូចក្រសួងនៃរដ្ឋាភិបាលដែរ គណៈកម្មការអាចបើកចំហនូវដំណើរការធ្វើច្បាប់ជូនចំពោះសង្គមស៊ីវិល តាមរយៈសិក្ខាសាលា វេទិកា និង កិច្ចពិភាក្សាសាធារណៈផងដែរ។

នីតិកម្មមិនថាត្រូវតែចាប់ផ្តើមនៅក្នុងក្រសួងមួយទេ។ សមាជិកណាមួយនៃរដ្ឋសភា ឬព្រឹទ្ធសភា អាចស្នើធ្វើច្បាប់បានដែរ។ នៅពេលសមាជិក រដ្ឋសភា ឬព្រឹទ្ធសភាម្នាក់ស្នើពង្រាងនោះ គេហៅថា "សេចក្តីស្នើច្បាប់" មិនមែនសេចក្តីព្រាងច្បាប់ទេ។ សេចក្តីស្នើច្បាប់មានដំណើរជាជំហាន មិនខុសគ្នាពីសេចក្តីព្រាងច្បាប់ទេ លើកលែងតែថាវាត្រូវបញ្ជូនទៅកាន់ គណៈកម្មការណាមួយនៅក្នុង រដ្ឋសភាតែម្តង។




# តើខ្ញុំត្រូវដាក់សម្ពាធទៅលើមន្ត្រីរដ្ឋាភិបាលយ៉ាងដូចម្តេច ?



- សរសេរសំបុត្របញ្ជូនតាមទូរសារ ឬ អ៊ីម៉ែល
- ហៅទូរស័ព្ទ
- គ្រោងពេលវេលាជួបទល់មុខគ្នា
- ចុះហត្ថលេខាលើបណ្តឹងទាមទារ
- ធ្វើការជួបជុំគ្នា ឬ ដង្ហែជាក្បួន
- រៀបចំកិច្ចពិភាក្សាសាធារណៈ
- ធ្វើឱ្យជាប់ទាក់ទងដល់អ្នកពាក់ព័ន្ធអន្តរជាតិ
- ចាប់ផ្តើមយុទ្ធនាការផ្សព្វផ្សាយ
- អញ្ជើញមន្ត្រីរដ្ឋាភិបាលឱ្យមកសួរសុខទុក្ខក្រុមអ្នករងគ្រោះ

**បញ្ចុះបញ្ចូលនៅទីនេះ !**

សមាជិកព្រឹទ្ធសភាមានអំណាចពិភាក្សា និងបោះឆ្នោតយល់ព្រម លើច្បាប់ ។
សូមទាក់ទងជាមួយគាត់ និងបញ្ចុះបញ្ចូលគាត់ឱ្យ គាំទ្រអ្នក ។




**បញ្ចុះបញ្ចូលនៅទីនេះ !**

ប្រធានរដ្ឋសភា គឺជាមនុស្សម្នាក់មួយរូបទៀតដែលមានអំណាច។ ប្រសិនបើយើងអាចធ្វើឱ្យប្រធានរដ្ឋសភាជឿថា ពង្រាងច្បាប់របស់យើងមានសារៈសំខាន់ សមាជិកដទៃទៀតនៃសភានីតិបញ្ញត្តិតែងតែធ្វើតាមជារឿយៗ។

**បញ្ចុះបញ្ចូលនៅទីនេះ !**

# ផែនការទំនាក់ទំនងជាយុទ្ធសាស្ត្រជាមួយរដ្ឋាភិបាល

នៅពេលដែលយើងបានកំណត់នូវប្រភេទខុសៗគ្នានៃអ្នកបញ្ញត្តិច្បាប់ដែលពាក់ព័ន្ធនិងការខិតខំក្នុងការធ្វើការតស៊ូមតិរបស់យើង ហើយនោះយើងអាចបង្កើតបាននូវផែនការទំនាក់ទំនងជាយុទ្ធសាស្ត្រមួយជាមួយរដ្ឋាភិបាល។

ផែនការទំនាក់ទំនងជាយុទ្ធសាស្ត្រជាមួយរដ្ឋាភិបាល បង្ហាញយ៉ាងពិស្តារនូវវិធីរបស់យើងក្នុងការបញ្ចុះបញ្ចូលមន្ត្រីរដ្ឋាភិបាលឱ្យឆ្លើយតបទៅនឹងយុទ្ធនាការតស៊ូមតិរបស់យើង។ ផែនការនេះនឹងត្រូវដាក់បញ្ចូលផងដែរនៅក្នុងផែនការសកម្មភាពតស៊ូមតិ (Advocacy Action Plan) របស់យើងដើម្បីធ្វើឱ្យសកម្មភាពនៃយុទ្ធនាការតស៊ូមតិនេះទទួលផ្តោតការយកចិត្តទុកដាក់ និង ស្ថិតទៅតាមគន្លងដែលបានគ្រោង។



## គំរូផែនការទំនាក់ទំនងជាយុទ្ធសាស្ត្រជាមួយរដ្ឋាភិបាល

**គោលបំណងជាក់លាក់** ៖ អនុម័ត និង អនុវត្តច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ក្នុងរយៈពេល ៥ឆ្នាំ។

| ច្បាប់ គោលនយោបាយ ឬ ការប្រតិបត្តិដែលនឹងត្រូវផ្លាស់ប្តូរ | អ្នកធ្វើសេចក្តីសម្រេច ដែលនឹងត្រូវកំណត់ជាអង្គគោលដៅ | ការយល់ដឹងជាសាធារណៈអំពីច្បាប់ | សកម្មភាពនានាដែលនឹងមានឥទ្ធិពលលើអ្នកធ្វើសេចក្តីសម្រេចដែលជាអង្គគោលដៅ | អ្នកគាំទ្រជើងឯក |
|---|---|---|---|---|
| **ឆ្នាំទី ១-២**<br>ច្បាប់មួយដែលធ្វើឱ្យអំពើហិង្សាក្នុងគ្រួសារ ក្លាយទៅជាឧក្រិដ្ឋកម្ម ត្រូវបានអនុម័ត | រដ្ឋសភា<br>ព្រឹទ្ធសភា<br>ព្រះមហាក្សត្រ | សាធារណជន មានការយល់ដឹងជាមូលដ្ឋានអំពីបញ្ហានៃអំពើហិង្សាក្នុងគ្រួសារ ប៉ុន្តែមានការយល់ដឹងតិចតួចអំពីសិទ្ធិស្របច្បាប់របស់ខ្លួន។<br>ប្រព័ន្ធផ្សព្វផ្សាយមានចំណេះដឹងកាន់តែទូលំទូលាយ | ពិនិត្យឡើងវិញនូវសេចក្តីព្រាងច្បាប់ថ្មី។ ដោយពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ធ្វើការផ្តល់យោបល់ដើម្បីធ្វើឱ្យសេចក្តីព្រាងច្បាប់បានប្រសើរឡើង រួមមានការដកយកចេញនូវករណីលើកលែងនៃបទរំលោភសេពសន្ថវៈរបស់ប្តីផង។<br>រៀបចំអត្ថបទពន្យល់ប្រាប់យ៉ាងសង្ខេប។ ជួបជាមួយប្រធានគណៈកម្មការនីតិកម្ម និង គណៈកម្មការសុខាភិបាល សង្គមកិច្ច ការងារ និងកិច្ចការនារី នៃព្រឹទ្ធសភា និង រដ្ឋសភា។<br>រៀបចំដំណើរទស្សនកិច្ចទៅកាន់កន្លែងជ្រកកោនរបស់អ្នករងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ ដើម្បីធ្វើឱ្យអ្នកបញ្ញត្តិច្បាប់ធ្វើការអង្កេត និង ជួបជាមួយអ្នករងគ្រោះ។<br>ជួបជាមួយនាយករដ្ឋមន្ត្រី គណៈរដ្ឋមន្ត្រី និងព្រះមហាក្សត្រ។<br>រៀបចំការដុតភ្លើងទៀនជាយុទ្ធនាការប្រឆាំងអំពើហិង្សាក្នុងខេត្តនីមួយៗក្នុងអំឡុងពេលយុទ្ធនាការ១៦ថ្ងៃ រួចហើយអញ្ជើញអ្នកបញ្ញត្តិច្បាប់ឱ្យមានប្រសាសន៍។ | លោកជំទាវ មូ សុខហួរ |
| **ឆ្នាំទី ៣-៥**<br>ច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ | រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ<br>រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | ច្បាប់មិនត្រូវបានអនុម័តទេ | ធ្វើការវិភាគប្រៀបធៀបដើម្បីពិនិត្យមើលថាតើប្រទេសដទៃទៀត អនុវត្តច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារយ៉ាងដូចម្តេច ?<br>ដោយពិគ្រោះយោបល់ជាមួយគណៈមេធាវីកម្ពុជា និង អ្នកពាក់ព័ន្ធដទៃទៀត បង្កើតពង្រាងសេចក្តីណែនាំដែលនឹងបង្ហាញប្រាប់លំអិតពីការប្រតិបត្តិដ៏ល្អបំផុតដែលនគរបាលព្រះរាជអាជ្ញា និង តុលាការ ត្រូវតែគោរពតាមនៅពេលដែលធ្វើការស៊ើបអង្កេត និង កាត់ក្តី។<br>ជួបជាមួយរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ នៅក្នុងក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ដើម្បីបញ្ចុះបញ្ចូលឱ្យអនុម័តនូវសេចក្តីណែនាំដោយក្រសួងទាំងពីរ ។<br>ជួយបង្កើតកម្មវិធីបណ្តុះបណ្តាលស្តីពីសេចក្តីណែនាំ សម្រាប់ប្រើប្រាស់នៅក្នុងសាលាភូមិន្ទនគរបាល សាលាភូមិន្ទចៅក្រម និង សាលាច្បាប់។ | លោកជំទាវ ឃឹម ចំរើន |

# ការជួបជាមួយសមាជិករដ្ឋាភិបាល

សមាជិករដ្ឋាភិបាលមានអំណាចក្នុងការជះឥទ្ធិពលទៅលើដំណើរការធ្វើច្បាប់ ប៉ុន្តែគេអាចមិនបានដឹងច្បាស់ពីយុទ្ធនាការតស៊ូមតិរបស់យើង។ យើងត្រូវត្រិះរិះប្រកបដោយប្រឌិតញាណ អំពីវិធីដែលត្រូវធ្វើឱ្យគេ យល់ដឹងអំពីកិច្ចប្រឹងប្រែងតស៊ូមតិរបស់យើង។ វិធីមួយក្នុងចំណោមវិធីល្អបំផុតក្នុងការផ្សព្វផ្សាយឱ្យដឹងពីសារតស៊ូមតិរបស់យើងទៅកាន់អ្នកធ្វើសេចក្តីសម្រេចដែលជាអង្គគោលដៅរបស់យើង គឺតាមរយៈការជួបដោយផ្ទាល់។

## តើខ្ញុំត្រូវជួបយ៉ាងដូចម្តេចជាមួយសមាជិករដ្ឋាភិបាលដើម្បីឱ្យមានប្រសិទ្ធភាព ?

ការជួបជាមួយសមាជិករដ្ឋាភិបាល អាចនាំឱ្យយើងមានការភ័យខ្លាច ដូច្នេះជាការឆ្លាតវៃប្រសិនបើបានត្រៀមរៀបចំសព្វគ្រប់ ដើម្បីឱ្យខ្លួនយើងកាន់តែមានទំនុកចិត្ត។ នេះគឺជាជំហានសំខាន់ទាំង ៤ ដើម្បីឱ្យមានភាពស័ក្តិសិទ្ធិក្នុងការជួបជាមួយសមាជិករដ្ឋាភិបាល។



អ្នកតស៊ូមតិមកពីអង្គការត្រួតពិនិត្យការបោះឆ្នោតជាច្រើន ជួបជាមួយ ឯកឧត្តម ស ខេង រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ។

### ជ្រើសរើស **ពេលវេលាដ៏សមរម្យ**

ការកំណត់ពេលវេលា គឺមានសារៈសំខាន់នៅពេលដែលស្នើឱ្យមានការជួបជាមួយសមាជិករដ្ឋាភិបាល ឬ បុគ្គលិករបស់គាត់។ យើងអាចស្នើឡើងឱ្យមានការជួបតាមរយៈការសរសេរលិខិត ទូរស័ព្ទ ឬក៏សុំឱ្យមិត្តភ័ក្តិស្នើសុំក្នុងនាមរបស់យើង ទោះបីជាយ៉ាងណាក៏ដោយ សមាជិកនៃរដ្ឋាភិបាលទំនងជាយល់ព្រមជួប ប្រសិនបើមានការយកចិត្តទុកដាក់ពីប្រព័ន្ធផ្សព្វផ្សាយថ្មីៗនេះ ឬ ប្រសិនបើយើងទើបតែបានជួបជុំគ្នារវាងអង្គការផ្សេងៗមួយក្រុម ដែលជាអ្នកគាំទ្រយុទ្ធនាការតស៊ូមតិរបស់យើង។

### ស្វែងយល់អំពី **ផលប្រយោជន៍** របស់គាត់

មុននឹងជួបជាមួយសមាជិករដ្ឋាភិបាលណាម្នាក់ យើងត្រូវតែព្យាយាមស្វែងយល់ថាតើគាត់មានទស្សនៈយ៉ាងដូចម្តេចចំពោះបញ្ហា? ហេតុអ្វីបានជាគាត់គួរគាំទ្រដល់យុទ្ធនាការតស៊ូមតិរបស់យើង ? តើគាត់អាចទទួលបានផលប្រយោជន៍យ៉ាងដូចម្តេចពីការធ្វើសកម្មភាពដែលយើងកំពុងស្នើឡើងនេះ ? តើសមាជិកម្នាក់ក្នុងមណ្ឌលបោះឆ្នោតរបស់គាត់ទទួលរងនូវឥទ្ធិពលយ៉ាងណា ? តើអ្វីទៅជាសំណើដ៏សមហេតុផលមួយដែលស្នើពីនរណាម្នាក់ក្នុងមុខតំណែងរបស់គាត់។ ប្រសិនបើយើងស្វែងយល់បានពីអ្វីដែលជាផលប្រយោជន៍របស់គាត់ ពេលនោះយើងនឹងអាចបញ្ចុះបញ្ចូលគាត់កាន់តែប្រសើរឡើងឱ្យគាំទ្រយុទ្ធនាការរបស់យើង។

### រៀបចំ **សេចក្តីអធិប្បាយសង្ខេបមួយ**

សេចក្តីអធិប្បាយសង្ខេប គឺជាឯកសារខ្លីមួយដែលសង្ខេបនូវគោលបំណងតស៊ូមតិរបស់យើង។ វាគួរតែមានប្រវែង ១ ទំព័រ និង មានចំណុច ៥ គឺ :

១-សារៈតានៃបញ្ហាដ៏ខ្លីមួយ
២-រឿងហេតុដោយផ្ទាល់ខ្លះៗដែលពាក់ព័ន្ធនឹងបញ្ហា
៣-អនុសាសន៍ដំណោះស្រាយបញ្ហារបស់យើង
៤-សេចក្តីស្នើសកម្មភាពរបស់យើងដែលអ្នកបញ្ញត្តិច្បាប់គួរតែធ្វើដើម្បីដោះស្រាយបញ្ហា
៥-ព័ត៌មានទំនាក់ទំនងរបស់យើង (ឈ្មោះ លេខទូរស័ព្ទ និង អាសយដ្ឋានអ៊ីម៉េល)

> **កំណត់សម្គាល់ :**
> រាល់អ្នកនាំសារទាំងអស់នៃយុទ្ធនាការតស៊ូមតិរបស់យើងគួរតែហាត់សូត្រ ឬ ទន្ទេញឱ្យចាំនូវធាតុទាំង ៥ នៃអត្ថបទពន្យល់ប្រាប់សង្ខេប ដើម្បីឱ្យពួកគេអាចសម្តែងយោបល់ជាធម្មតា និង គួរជាទីទុកចិត្ត នៅពេលដែលជួបជាមួយសមាជិករដ្ឋាភិបាល ។

### រំពឹងថានឹងមាន **សកម្មភាព**

មានវិធីជាច្រើន ដែលសមាជិករដ្ឋាភិបាលម្នាក់អាចគាំទ្រដល់យុទ្ធនាការតស៊ូមតិរបស់យើង។ យើងអាចចង់ឱ្យគាត់បោះឆ្នោតគាំទ្រពង្រាងច្បាប់របស់យើង។ យើងអាចនឹងឱ្យគាត់ដឹកនាំ និង ណែនាំ ឬក៏ប្រហែលជាយើងគ្រាន់តែចង់កសាងទំនាក់ទំនងឱ្យកាន់តែរឹងមាំជាងមុនប៉ុណ្ណោះ។ អ្វីដែលយើងរំពឹងចង់បាននោះមិនមែនទូលំទូលាយមិនច្បាស់លាស់នោះទេ។ ការជួបនេះគួរបញ្ចប់ដោយឱ្យគាត់ យល់ព្រមលើសកម្មភាពណាមួយជាក់លាក់។

**ក្នុងពេលជួបនេះ សូមកុំភ្លេចស្តាប់ឱ្យបានសកម្ម ហើយនិយាយឱ្យបានម៉ឺងម៉ាត់ ឯ** មុនពេលចាកចេញ ចូរផ្តល់ជូនសមាជិករដ្ឋាភិបាលនូវសេចក្តីអធិប្បាយសង្ខេបមួយច្បាប់ រួចហើយសម្តែងនូវការអរគុណចំពោះការផ្តល់ឱកាសឱ្យជួបនេះ។ ក្រោយមក ចូរផ្ញើនូវលិខិតបញ្ជាក់ (Follow-up letter) ពីអ្វីដែលបានពិភាក្សា និង ពីសកម្មភាពដែលគាត់បានយល់ព្រមរួចហើយថានឹងធ្វើនៅពេលអនាគត។ សូមកុំភ្លេច ធ្វើឱ្យគាត់ប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវការព្រមព្រៀងគ្នាទាំងនេះ។

# សេចក្តីសន្និដ្ឋាន

ការយល់ដឹងអំពីទំនាក់ទំនង អំពីអំណាច និង អំពីការបញ្ចុះបញ្ចូល គឺសុទ្ធតែជាជំហានដ៏សំខាន់ទាំងអស់ក្នុងការបង្កើតទំនាក់ទំនងដ៏រឹងមាំជាមួយសមាជិករដ្ឋាភិបាល។ ជាមួយនឹងជំនាញទាំងនេះ យើងអាចបង្កើតទំនាក់ទំនង និង បញ្ចុះបញ្ចូលមនុស្សដែលមានអំណាចឱ្យគាំទ្រយុទ្ធនាការតស៊ូមតិរបស់យើង និង ជាចុងក្រោយឱ្យបំពេញនូវគោលដៅតស៊ូមតិរបស់យើង។

នៅក្នុងសៀវភៅទីបីរបស់យើង គឺ **"ការធ្វើការជាមួយប្រព័ន្ធផ្សព្វផ្សាយ"** យើងនឹងរកឱ្យឃើញថាតើយើងអាចប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយយ៉ាងដូចម្តេចដើម្បីបញ្ជូនសារតស៊ូមតិរបស់យើង និង ដើម្បីទទួលបានការគាំទ្រចំពោះយុទ្ធនាការតស៊ូមតិរបស់យើង។



# សទ្ទានុក្រម

**បញ្ជាក់អះអាង**

គាំទ្រ បញ្ជាក់ថាពិត ឬ ថ្លែងជាវិជ្ជមាន។

**ផ្លាកសញ្ញា**

សញ្ញាសម្គាល់ដែលអាចមើលឃើញ ប្រភេទ ឬ ឈ្មោះ ដែលធ្វើឱ្យរបស់អ្វីមួយឃើញថាប្លែកពីរបស់មួយទៀត។

**អ្នកទទួលផល**

អ្នកដែលទទួលបានកិច្ចសង្គ្រោះ ប្រាក់កាស ទ្រព្យសម្បត្តិ អំណោយ ឬ ផលប្រយោជន៍ដទៃទៀត។

**អ្នកគាំទ្រជើងឯក**

អ្នកបញ្ញត្តិច្បាប់ដែលនឹងប្រើប្រាស់មុខតំណែង ឬ ឥទ្ធិពលរបស់គាត់ដើម្បីជំរុញអង្គហេតុ ឬ បញ្ហាមួយ។

**ប្រជាពលរដ្ឋក្នុងមណ្ឌល**

អ្នកស្រុក ឬ សមាជិកនៃក្រុមមួយដែលតំណាងដោយមន្ត្រីម្នាក់ដែលជាប់ឆ្នោត។ ក្រុមប្រជាពលរដ្ឋដែលផ្តល់សិទ្ធិអំណាចដល់មនុស្សម្នាក់ឱ្យធ្វើជាអ្នកតំណាងរបស់ខ្លួន។

**ផ្សព្វផ្សាយ**

ផ្សាយយ៉ាងទូលំទូលាយ, បាចសាច, ចរាចរ ឬ ចែកចាយ។

**បញ្ចុះបញ្ចូល**

ព្យាយាមធ្វើឱ្យអ្នកបញ្ញត្តិច្បាប់ ឬ មន្ត្រីសាធារណៈផ្សេងទៀតជឿនិងគាំទ្រ ឬ ប្រឆាំងនឹងអង្គហេតុជាក់លាក់មួយ។

**អ្នកពាក់ព័ន្ធ**

អ្នកដែលមានផលប្រយោជន៍ដោយផ្ទាល់នៅក្នុងលទ្ធផលនៃយុទ្ធនាការតស៊ូមតិរបស់យើង។

**អន្តគោលដៅ**

អ្នកពាក់ព័ន្ធដែលមានលទ្ធភាពខ្ពស់បំផុតក្នុងការជះឥទ្ធិពលទៅលើជោគជ័យ ឬ បរាជ័យនៃយុទ្ធនាការតស៊ូមតិរបស់យើង។




## ឯកសារយោង

សម្រាប់ព័ត៌មានបន្ថែមអំពីប្រធានបទទាំងនេះ សូមអាន :

**An Introduction to Advocacy: Training Guide**
Ritu Sharma (SARA Project), USAID Office of Sustainable Development.

**Advocacy: Building Skills for NGO Leaders**
The Centre for Development and Population Activities (CEDPA) (1999).

**A New Weave of Power, People & Politics: The Action Guide for Advocacy and Citizen Participation**
Lisa VeneKlasen with Valerie Miller, World Neighbors (2002).

**វេបសាយ របស់រាជរដ្ឋាភិបាលកម្ពុជា**
Http://www.cambodia.gov.kh
Http://www.khmersenate.org

សញ្ញាណទូទៅអំពីដំណើរការតុលាការនៅកម្ពុជា
ដោយ កុយ នាម អង្គការមូលនិធិអាស៊ី (១៩៩៨)
**Introduction to the Cambodian Judicial Process**
Koy Neam, The Asia Foundation (1998).

**Advocacy in Action: A Toolkit to Support NGOs and CBOs Responding to HIV/AIDS**
International HIV/AIDS Alliance (2003).

**Managing Partnerships: Tools for Mobilising the Public Sector, Business and Civil Society as Partners in Development**
Ros Tennyson, The Prince of Wales Business Leaders Forum (1989).

**ការឃ្លាំមើលសមាជិកសភា ‑ របាយការណ៍ស្តីពីដំណើរការនៃសម័យប្រជុំរដ្ឋសភា អាណត្តិទី ២ (១៩៩៨‑២០០៣)**
ដោយ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (២០០៣)